# ការសំភាសន៍របស់អ៊ុំប្រុស ផុន ផុស

កៈ  អ្នកដែរសំភាសន៍ ជាង ស៊ីអ៊ារ        ខៈ  អ្នកដែរអោយគេសំភាសន៍ ផុន ផុស

<u>ការសង្ខេបប្រវត្តិរបស់ អ៊ុំប្រុស ផុន ផុស</u>

អ៊ុំប្រុស ផុន ផុស មានអាយុ អ៊ុំប្រុស មានភេទប្រុស អ៊ុំប្រុស មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្ទឹងជ្រៅ សង្កាត់ដើមមាន ស្រុកតាខ្មៅ នឹងខេត្តកណ្តាល។

កៈ  ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរ មានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ  បាទ!!ព្រមនឹង

កៈ  បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី6ខែ4 ឆ្នាំ2018 ធ្វើនៅភូមិ4 ច្រឡុំភូមិ4គឺនៅភូមិ

ខៈ  ភូមិស្ទឹងជ្រៅ

កៈ  ភូមិស្ទឹងជ្រៅណាអ៊ុំ?

ខៈ  សង្កាត់ដើមមាន

កៈ  សង្កាត់ដើមមាន ចុះខ័ណ្ឌ?

ខៈ  ស្រុកតាខ្មៅ នៅខេត្តកណ្តាល

ក៖ ចឹងនៅខេត្តកណ្តាលណាអ៊ុំ
បាទចឹងសំរាប់អ៊ុំមានឈ្មោះពេញនឹងមានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ ខ្ញុំបាទមានឈ្មោះផុន ផុស

ក៖ ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ ខ្ញុំអត់មានដាក់ផងនឹងខ្ញុំដាក់តែប៉ុណ្ណឹង

ក៖ អូ៎!!បាទចុះកាលពីនៅក្មេងៗៗនឹងមានធ្លាប់មាននរណាហៅឈ្មោះអ៊ុំអីផ្សេងដែរទេ?

ខ៖ ខ្ញុំគេហៅឈ្មោះតាភ័សអីចឹងទៅណាស់

ក៖ អូ៎!!ហៅឈ្មោះភ័សហោសអ៊ុំ?

ខ៖ រឺហៅផុស ភ័សអីចឹង

ក៖ ចឹងហៅផុស ភ័សណាអ៊ុំចុះអ៊ុំមានអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំអាយុ58ឆ្នាំ

ក៖ ចុះអ៊ុំដឹងថាអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរអ៊ុំ?

ខ៖ ខ្ញុំអត់ចងចាំទេក្មួយចេះគិតដែរទេ ខ្ញុំដូចជា1960គត់ម៉េចទេនេះ កើតនៅឆ្នាំ1960

ក៖ ចឹងអ៊ុំកើតនៅឆ្នាំ1960ណាអ៊ុំ ប៉ុន្តែថ្ងៃខែអ៊ុំអត់មានចងចាំទេណ?

ខ៖ ខ្ញុំអត់បានចងចាំទេណាស់

ក៖ អូ៎!!អត់អីទេអ៊ុំ?

ខ៖ ខ្ញុំស្តាយណាស់ដែរខ្ញុំមិនបានប្រាប់ហាស

ក៖ បាទអ៊ុំ ចុះអ៊ុំឆ្នាំខ្មែរនឹងអ៊ុំកើតនៅឆ្នាំអីគេដែរអ៊ុំ លក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖ ឆ្នាំខ្មែរហោស?

ក៖ បាទអ៊ុំឆ្នាំជូត ឆ្លូវ ខាល ថោះអ៊ុំឆ្នាំអីគេដែរទៅអ៊ុំ?

ខ៖ អូ៎!!ខ្ញុំឆ្នាំឆ្លូវ ហេឆ្នាំជូតហី អូឆ្នាំជូតនឹងហាស

កៈ ចឹងអ៊ុំឆ្នាំជូត ចុះអ៊ុំកើតនៅឆ្នាំណាដែរអ៊ុំ?

ខៈ ខ្ញុំកើតនៅក្របៅអាចម៍កុកហោសស្រុកកំណើតហោស

កៈ ក្របៅអាចម៍កុកនឹងនៅណាដែរអ៊ុំ?

ខៈ នៅខាងក្រោមព្រែកហូរនឹង

កៈ នៅក្រោមព្រែកហូរ ប៉ុន្តែនៅភូមិអី ឃុំអីគេដែរអ៊ុំ?

ខៈ កាលណុងមុនបើនិយាយទៅយើងនៅស្រុកតាខ្មៅដែរនឹងហាស
នៅខេត្តកណ្តាលដែរនឹងហាស

កៈ នៅស្រុកតាខ្មៅប៉ុន្តែភូមិអីគេដែរអ៊ុំ?

ខៈ នៅភូមិក្របៅអាចម៍កុក

កៈ ចុះនៅឃុំអីគេដែរទៅអ៊ុំ?

ខៈ នៅឃុំហាសកាលពីមុននឹងជ្រែកយោងចឹងហាសណាស់

កៈ ឃុំជ្រែកយោងណាអ៊ុំ?

ខៈ បាទកាលពីជំនាន់សង្គមហាស

កៈ បាទអ៊ុំ ចុះសំរាប់អ៊ុំមានបងប្អូនចំនួនប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំមានបងប្អូន7នាក់នឹងហាស

កៈ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនទី2

កៈ ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ មើលបងប្អូន7នាក់ មានស្រី2នាក់ចឹងមានប្រុស5នាក់ហោស

កៈ ចឹងមានស្រី5នាក់ នឹងប្រុស2នាក់នឹងហោស វាមាន8នាក់ហើអ៊ុំ?

ខៈ អត់ទេមាន7នាក់ទេនឹង

កៈ អូ៎!!មានតែ7នាក់ទេហោសអ៊ុំ
ចុះបងប្អូនរបស់អ៊ុំនឹងមានឈ្មោះអីគេខ្លះដែរទៅអ៊ុំមានចងចាំទេ?

ខៈ មានឈ្មោះផុន លាប មានឈ្មោះផុស ផុន ហើយនឹងមិនបាច់និយាយទេ

កៈ បាទៗៗអ៊ុំបាទ?

ខៈ ហើយនឹងមានឈ្មោះផុន តូច មានឈ្មោះលាស់ មានឈ្មោះផុន ថា

កៈ មានឈ្មោះផុន ថា ហើយចឹង?

ខៈ វាបានប៉ុន្មាននាក់ដែរហើយនឹងហោសអ៊ុំ?

កៈ ខ្ញុំភ្លេចបាត់ហើយនឹងអ៊ុំ?

ខៈ វាមើលបាន5នាក់ហើយណា

កៈ ហើយចុះប្អូនរបស់អ៊ុំទៀតនឹងហាស?

ខៈ អាប្អូនតូចៗៗនឹងវាមិនបានដឹងទេ

កៈ ចឹងអ៊ុំអត់មានចងចាំឈ្មោះទេណាអ៊ុំ?

ខៈ បាទអត់ចងចាំទេ

កៈ បាទអ៊ុំ ចុះអ៊ុំមានចងចាំថាកាលអ៊ុំនៅក្មេងៗៗ
ប៉ុណ្ណឹងអីនឹងអ៊ុំមានធ្លាប់បានលេងអីគេខ្លះជាមួយបងប្អូនរបស់អ៊ុំដែរ?

ខៈ លេងតែបិទពួន

កៈ លេងបិទពួន លេងឡឹកបាយឡ?

ខៈ លេងអីចឹងទៅណាស់

កៈ លេងបាញ់ឃ្លី នឹងលេងគប់ឈូសអីចឹងទៅណាអ៊ុំ?

ខៈ បាទក្រៅពីនឹងនៅប៉ុននេះនឹង អត់ទាន់មានលេងឈូសទេ

កៈ អូ៎!!ចឹងអត់ទាន់មានទេហោសអ៊ុំ?

ខ៖ បាទ!!មានទាល់លេងនឹងហាស លេងអីគប់វង្ស មានទាន់មានឈូសណា លេងគប់នឹងហាស រួចហើយនឹង
មានដល់ថ្នាក់ប៉ុននេះនឹងច្រូតស្មៅគោជាមួយបងប្អូនអីនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ បើបាញ់ឃ្លីអីនឹងមាន

ក៖ ប៉ុន្តែមានលេងទាល់បាល់អីដែរតើហីអ៊ុំ?

ខ៖ អត់មានទេ កាលខ្ញុំនៅពីតូចៗៗនឹងអត់មានទេណាស់

ក៖ អូ៎!!បាទអ៊ុំទៅច្រូតស្មៅគោអីចឹង?

ខ៖ បាទមើលប្អូនអីចឹងទៅណាស់ចុះខ្ញុំទី2ហោស

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ហើយនឹងដាំបាយចឹងទៅ

ក៖ ប៉ុន្តែអ៊ុំចូលចិត្តធ្វើអីគេតែម្តងនឹងជាមួយបងប្អូនរបស់អ៊ុំនឹង?

ខ៖ ចូលចិត្តហោស ចូលចិត្តតែប្រលែងលេងចឹងទៅនៅលើផ្ទះនឹង

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ លេងសើចមកពីនេះហាសដឹងក្តីប៉ុនៗៗនេះហាស

ក៖ បាទអ៊ុំបាទចឹង?

ខ៖ ចូលចិត្តលេងចឹងទៅហើយ
ពេលនៅនោះកំសត់ណាស់អូនអើយនៅកំបៅអាចម៍កុកនឹង

ក៖ អូ៎!!បាទអ៊ុំបាទ ចុះអ៊ុំ?

ខ៖ ស្រុកសង្គ្រាមហាស ស្រុកជួបសង្គ្រាមហាស

ក៖ បាទអ៊ុំបាទចុះ?

ខ៖ ជួបពេកនឹងហាស ចុះកាលណុងខ្ញុំជួបនៅប៉ុណ្ណឹងខ្ញុំជួបហាស

កៈ ចុះសំរាប់អ៊ុំគិតថាបងប្អូនរបស់អ៊ុំនឹងសព្វថ្ងៃពួកគាត់នៅណាដែរអ៊ុំ?

ខៈ បានស្លាប់ទាំងអស់នឹង

កៈ អូ៎!!ចឹងស្លាប់ទាំងអស់តែម្តងហោសអ៊ុំ?

ខៈ អស់រលីងតែម្តងនឹងទាំងម៉ែទាំងឪនឹងតែម្តងនឹងស្លាប់ទាំងអស់នឹង

កៈ ចឹងនៅសល់តែអ៊ុំមួយទេហោសអ៊ុំ?

ខៈ បាទនៅសល់តែខ្ញុំមួយទេទោលតែម្នាក់ឯងនឹង

កៈ ចុះសំរាប់ម្តាយរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរទៅអ៊ុំ?

ខៈ គាត់មានឈ្មោះកង ងួន

កៈ ចុះគាត់បើមកដល់ឥឡូវនឹងមានដឹងថាគាត់ប្រហែលជាអាយុប៉ុន្មានដែរទេអ៊ុំ?

ខៈ ឥឡូវនឹងអាយុគាត់នឹង70ឆ្នាំនឹងហាស

កៈ ប៉ុន្តែគាត់ស្លាប់បាត់ហើយណអ៊ុំ?

ខៈ គាត់ស្លាប់បាត់ហើយនឹង

កៈ ប៉ុន្តែម្តាយរបស់អ៊ុំនឹងគាត់បានកើតនៅណាដែរអ៊ុំ ម្តាយរបស់អ៊ុំហាស?

ខៈ គាត់កើតនៅក្របៅអាចម៍កុកដែរនឹង

កៈ ចុះឪពុករបស់អ៊ុំវិញហាសអ៊ុំ?

ខៈ គាត់នៅក្របៅអាចម៍កុកដែរនឹង

កៈ ប៉ុន្តែឪពុករបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរទៅអ៊ុំ?

ខៈ គាត់មានឈ្មោះផន ផុន

កៈ ប៉ុន្តែទាល់ឥឡូវនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរតៅអ៊ុំ?

ខៈ គាត់អាយុ80ឆ្នាំនឹង

កៈ គាត់អាយុ80ឆ្នាំ អូយាយគាត់អាយុបងតាហោសអ៊ុំ?

ខ៖ បាទគាត់បងប្រពន្ធ

ក៖ អូ៎!!ប្រពន្ធបងប្ដីហើអ៊ុំ?

ខ៖ អត់ទេប្រពន្ធអាយុ70ឆ្នាំនឹងហើយឪពុករបស់ខ្ញុំមិញនឹងអាយុ80ឆ្នាំ

ក៖ អូ៎!!ចឹងហោសអ៊ុំ
ចុះឪពុករបស់អ៊ុំកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ គាត់ចិញ្ចឹមជីវិតនឹងគាត់ធ្វើនេះគាត់នេសាទនឹង

ក៖ គាត់នេសាទត្រីណាអ៊ុំ?

ខ៖ បាទ!!គាត់នេសាទត្រីនឹងហាស

ក៖ ចឹងគាត់នេសាទតែត្រីទេគាត់អត់មានធ្វើស្រែចំការទេណាអ៊ុំ?

ខ៖ គាត់ធ្វើដែរនឹងពេលខែពង្រុះគាត់ពង្រុះ

ក៖ អូ៎!!បាទអ៊ុំបាទចឹង?

ខ៖ ជំនាន់ណុងពង្រុះស្រូវទេណាស់ ពង្រុះស្រូវនៅទួលក្រសាំងនឹងហាស

ក៖ បាទអ៊ុំបាទ ចុះគាត់កាចរឺមួយក៏ស្លូតឪពុករបស់អ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំនឹងគាត់ស្លូតទេ ប៉ុន្តែអ្នកដែរធ្វើអោយកាចនឹងគាត់កាច?

ក៖ ចឹងហោសណាអ៊ុំ?

ខ៖ បាទគាត់ស្លូតសឹងអីហើយនឹង?

ក៖ អូ៎!!បាទអ៊ុំបាទនឹងហើយ?

ខ៖ ប៉ុន្តែបើគេធ្វើអោយគាត់កាចនឹងគាត់ាកចចឹងទៅណាស់

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ប៉ុន្តែគាត់ស្អប់ចឹងទៅណាស់ប៉ុន្តតែទើបតែស្អប់នៅជំនាន់អាពតនឹងទេ

ក៖ អូ៎!!ចឹងហោសបាទអ៊ុំបាទ?

ខ៖ អាពតគេបានសំលាប់បងប្អូនរបស់គាត់ចឹងគាត់បានសំលាប់គេវិញចឹងទៅណាស់

ក៖ អូ៎ៗគាត់ខឹងគាត់ហោសអ៊ុំ?

ខ៖ បាទនៅចឹងទេបើថាពីសង្គមនឹងគាត់អត់មានទេ

ក៖ ចឹងគាត់ស្លូតទេណាអ៊ុំណា?

ខ៖ បាទ!!គាត់ស្លូតទេនឹង

ក៖ ចុះសំរាប់ម្តាយរបស់អ៊ុំវិញគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ ម្តាយរបស់ខ្ញុំនឹងសំរាប់តែលក់ត្រីអោយឪពុករបស់ខ្ញុំនឹងហាស

ក៖ អូ៎!!ចឹងឪពុករបស់អ៊ុំអ្នកនេសាទ ហើយឪពុករបស់អ៊ុំអ្នកលក់ត្រី?

ខ៖ គាត់អ្នកនេសាទ ហើយម្តាយគាត់អ្នកលក់ត្រីនឹង

ក៖ អូ៎!!បាទ ចុះសំរាប់គាត់កាចរឺមួយក៏ស្លូតដែរម្តាយរបស់អ៊ុំនឹង?

ខ៖ គាត់ស្លូតណាស់គាត់នឹង

ក៖ ចឹងហោសអ៊ុំណាអ៊ុំ?

ខ៖ គាត់មិនដែរចេះវៃកូនទេមិនដែរបានជេអីទេនឹង

ក៖ អូ៎!!បាទចុះអ៊ុំមានធ្លាប់មានចងចាំថាកាលអ៊ុំនៅជាមួយពួកគាត់
អ៊ុំធ្លាប់មានប្រវត្តិអនុស្សាវរីយ៍អីជាមួយគ្នាដែរទេអ៊ុំ ធ្លាប់ទៅស្រែធ្លាប់អីចឹងហាស?

ខ៖ មានដែរតើ!!នឹង

ក៖ អ៊ុំមានបានធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខ៖ មានដូចជានៅជាមួយម្តាយនឹង ចេះធ្វើកិច្ចការងារនៅផ្ទះចឹងទៅណាស់

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ហើយនឹងចេះធ្វើស្មៅអីចឹងទៅណាស់ នឹងចេះបោចស្មៅនៅក្នុងស្រូវអីចឹងទៅ

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ហើយនឹងទៅដាក់លបជាមួយឪពុកអីចឹងទៅណាស់

ក៖ បាទអ៊ុំបាទនឹងហើយ?

ខ៖ ទៅធ្វើនេសាទនឹងជាមួយគាត់ចឹងទៅ នឹងរកត្រីអីចឹង

ក៖ អូ្!!បាទអ៊ុំ
ចុះអ៊ុំគិតថាឪពុករបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខ៖ គាត់ប្រាប់ដែរតើនឹង

ក៖ គាត់ថាគាត់ធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខ៖ គាត់ថាកូនអើយយើងក្រចឹងហាសណាស់យើងចេះតែដាក់លបអីចឹងទៅ
យើងធ្វើស្រែទំលុសអីចឹង ទៅណាស់

ក៖ អត់អីទេអ៊ុំអចផ្អកមួយម៉ាត់សិនទៅអ៊ុំ

ខ៖ បាទចឹងនឹង

ក៖ ចុះម្ដាយរបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីក្មេងទៅអ៊ុំដែរទេ?

ខ៖ គាត់ប្រាប់ដែរនឹងគាត់ថាគាត់នឿយចឹងទៅណាស់ គាត់មានតែលក់ត្រី

ក៖ អូ្!!បាទអ៊ុំបាទ?

ខ៖ គាត់ទូលត្រីលក់ហាស

ក៖ បាទអ៊ុំបាទនឹង?

ខ៖ គាត់មកផ្សាររបស់យើងនៅតាខ្មៅនឹងហាស មកពីក្របៅអាចម៍កុកចឹងហាស

ក៖ អូ្!!ចឹងហោសអ៊ុំ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ខាងឪពុកហោសខ្ញុំស្គាល់ ផន ប៉ាច

ក៖ នឹងខាងឪពុក តាមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ តាមានឈ្មោះផន

កៈ ដល់ពេលយាយនឹងមានឈ្មោះប៉ាច?

ខៈ នឹងហើយយាយមានឈ្មោះប៉ាច

កៈ ចុះយាយតាខាងម្តាយវិញអ៊ុំ?

ខៈ គាត់មានឈ្មោះកង ម៉ន

កៈ តាមានឈ្មោះកង?

ខៈ បាទ ហើយយាយនិងមានឈ្មោះម៉ន

កៈ អូ៎!!បាទ ចុះយាយតាខាងឪពុកគាត់នៅណាដែរអ៊ុំមានដឹងទេ?

ខៈ នៅស្រុកកំណើតនៅនឹងដែរនឹង

កៈ ចឹងហោសអ៊ុំ ចុះយាយតាខាងម្តាយវិញ?

ខៈ នៅខាងម្តាយនឹងក៏នៅជាមួយគ្នានៅនឹងដែរនឹង

កៈ អូ៎!!បាទអ៊ុំបាទនឹង?

ខៈ នៅម្តុំគ្នាទាំងអស់ដែរនឹងជីដូនមួយគ្នាទាំងអស់នឹង នៅក្បាលអាចម៍កុកនឹងហាស

កៈ បាទអ៊ុំបាទ ចុះសំរាប់អ៊ុំមកនៅនឹងយូរនៅអ៊ុំ?

ខៈ មកនៅតាំងពីឆ្នាំ1979នឹង

កៈ នៅឆ្នាំ1979នឹងរហូតមកដល់តឡូវនឹងវាប្រហែលជាអស់38-39ឆ្នាំណាអ៊ុំ?

ខៈ បាទនឹងហើយ

កៈ បាទអ៊ុំ ចុះអ៊ុំគិតថាមានបងប្អូនរឺមួយក៏កូនចៅណាដែរទៅរស់នៅក្រៅប្រទេសទេអ៊ុំ?

ខៈ ខ្ញុំនៅខាងខ្ញុំនឹងអត់មានទេ

កៈ ប៉ុន្តែលក្ខណៈថាទៅធ្វើការងារនៅថៃ នៅវៀតណាម នៅកូរ៉េ
នៅជប៉ុនអីអត់មានទេហោសអ៊ុំ?

ខៈ អត់មានទេនឹង អត់តែម្តងនឹងកូនរបស់ខ្ញុំនឹងវាខ្លាចណាស់វាមិនហ៊ានទៅនឹងគេទេ

កៈ  បាទអ៊ុំបាទនឹង?

ខៈ  និយាយទៅវាអត់ហ៊ានតែម្តងនឹង

កៈ  ចុះសំរាប់អ៊ុំភរិយារបស់អ៊ុំនឹងមានឈ្មោះអីគេដែរទៅអ៊ុំ?

ខៈ  មានឈ្មោះឆោម ចាប

កៈ  ចុះអ៊ុំមានចងចាំថាអ៊ុំបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខៈ  រៀបនៅក្នុងឆ្នាំ1982 ចឹងទើបតែការឥឡូវនឹងដែរនឹង

កៈ  នៅឆ្នាំ1982នឹងហោស?

ខៈ  នៅឆ្នាំ1982នឹងយូន គ្រាន់ពេលដែរឯងបាក់ជើងមែនទេ នៅទេកំពុងធ្វើសង្គ្រាម

កៈ  អូ៎!!នៅឆ្នាំ1982នឹងចឹងវាអស់36ឆ្នាំនៅពេលដែរអ៊ុំការនឹង?

ខៈ  បាទនឹងហើយ

កៈ  ចុះនៅពេលដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍នឹងគិតថាអ៊ុំជាអ្នករៀបចំដោយចិត្តឯង រឺមួយឪពុកម្តាយជាអ្នករៀបចំអោយដែរអ៊ុំ?

ខៈ  ឪពុកម្តាយជាអ្នករៀបចំអោយនឹង

កៈ  ប៉ុន្តែមានជាជំនូនជូនអ៊ុំស្រីទេ?

ខៈ  អោយកាលពីជំនាន់ណុងអោយប៉ុន្មានទេ
អោយលុយខ្មែរហោសលុយខ្មែរពេលណុងចាយហើយនឹង
កាលណុងគេថាជំនាន់600ម៉េចគេទេនឹង

កៈ  បាទចឹងហោសអ៊ុំ?

ខៈ  កាលណុងលុយថ្លៃហាសណាស់ ទេកាលណុងអត់ទាន់មានក្រដាស់50ផងនឹង

កៈ  ប៉ុន្តែលុយថ្លៃមែនទេអ៊ុំ?

ខៈ  បាទលុយថ្លៃកាលណុង

កៈ  ចុះអ៊ុំកាលណុងអ៊ុំអោយប៉ុន្មានដែរទៅអោយ600?

ខ៖  បាទ កាលណុង600នឹងលុយថ្លៃហាសណាស់នឹងហើយអោយចឹង
មានណាកាលណុងប្រាក់ខែគាត់ នឹងជំនាន់ណុងប្រាក់ខែ50នឹង
តែយើងអោយថ្លៃថ្នូះចឹងហាស

ក៖  បាទអ៊ុំបាទ?

ខ៖ កាលណុងអោយប៉ុណ្ណឹងថ្លៃជាងគេជាងឯងហើយនាងឯងនឹង ពេលណុងលុយចំបក
លុយយួនហោស

ក៖  បាទអ៊ុំបាទនឹង?

ខ៖  បាទលុយជំនាន់គាត់ជួយយើងហោស

ក៖  បាទអ៊ុំបាទ ចុះអ៊ុំគិតថាអ៊ុំស្គាល់អ៊ុំស្រីដោយរបៀបណាដែរអ៊ុំ?

ខ៖  ស្គាល់គ្នាដូចថានៅថ្នះជិតគ្នាចឹងទៅណាស់

ក៖  អូ៎!!ចឹងហោសអ៊ុំ?

ខ៖  បាទចេះតែមើលគ្នាឃើញចឹងទៅ ថ្នះនៅត្រើយមួយខាងគេនៅក្រោយខាងនេះ

ក៖  ស្គាល់យូរដែរហើយណអ៊ុំ?

ខ៖  ស្គាល់យូរហោប្រហែលជា2-3ខែនឹងហាស

ក៖  បានស្គាល់2-3ខែនឹងអ៊ុំចាប់ផ្តើមចូលស្តីគាត់តែម្តងនឹងអ៊ុំ?

ខ៖  បាទនឹងហើយចឹង

ក៖  អូ៎!!ចឹងលឿនដែរនឹងហោសអ៊ុំ?

ខ៖  បាទនឹងហើយថាអត់ទុកស្អែកទេ

ក៖  ចុះអត់ទុកស្អែកទេហោសអ៊ុំ?

ខ៖  ថាអត់ទុកស្អែកទេអាគ្នាឃ្លានហើយត្រូវតែឆាន
ម៉េចហ៊ានទុកស្អែកបើទុកស្អែកនឹងខ្លែងចេះហោះហើយនឹង ចុះគេស្តីគ្រប់គ្នាដែរនឹង

ក៖  ចឹងពេលណុងមានមនុស្សច្រើនចង់ចូលស្តីគាត់ច្រើនហោសអ៊ុំ?

ខ៖  មានមនុស្សច្រើនចូលដែរនឹង

ក៖  អ៎ូ!!ចឹងអ៊ុំត្រូវប្រញាប់ដែរហោសអ៊ុំ?

ខ៖  អ៎ូ!!វេទនាណាស់

ក៖  ចឹងសំរាប់អ៊ុំដូចជាអ៊ុំនឹងរៀនបានថ្នាក់ទីប៉ុន្មានដែរទៅអ៊ុំ?

ខ៖  ខ្ញុំអត់បានរៀនទេនៅនឹងហោស វល់តែកៀរអាពតធ្វើបាបនឹងហាស

ក៖  ប៉ុន្តែអ៊ុំមានចេះភាសាអីផ្សេងក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខ៖  អត់មានចេះទេ ចេះតែភាសាខ្មែរសុទ្ធនឹងហាស

ក៖  ភាសាវៀតណាម ថៃអីនឹងអ៊ុំអត់ចេះដែរនឹង?

ខ៖  អត់មានចេះទេនឹង

ក៖  អ៎ូ!!ចុះអ៊ុំធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខ៖  អត់មានស្និទ្ធិស្នាលអីទេ អូមានតែមួយទេនោះ

ក៖  នរណាគេដែរទៅអ៊ុំ?

ខ៖  មានជំនាន់ឆ្នាំ1979ដល់ឆ្នាំ1975នឹងមានតែមួយនឹងនឹងជិតស្និទ្ធិគ្នាតែម្តងនឹង

ក៖  អ៎ូ!!ចឹងហោសអ៊ុំណា?

ខ៖  បាទនឹងហើយចឹង

ក៖  ចុះអ៊ុំធ្លាប់បានធ្វើអីគេខ្លះដែរជាមួយគាត់ហាសអ៊ុំ?

ខ៖  ធ្វើអីគេ?

ក៖  ដូចជាថាធ្លាប់បានលេងអីគេខ្លះដែរជាមួយគាត់ចឹងហាស
ជាមួយមិត្តភក្តិជិតស្និទ្ធិរបស់អ៊ុំហាស?

ខ៖  បានតែលេងសើចជាមួយគ្នាចឹងទៅ បានតែលេងស្មៅស្រូវ
ស្មៅពោតអីជាមួយគ្នាចឹងទៅណាស់

កៈ អ៊ូៗចឹងណាអ៊ុំ?

ខៈ បាទ!!សប្បាយជាមួយគ្នាចឹងទៅណាស់

កៈ អ៊ូ!!បាទអ៊ុំបាទ
ចុះអ៊ុំគិតថាអ៊ុំទៅធ្វើការងារនៅវាលស្រែនឹងអ៊ុំធ្លាប់បានទៅធ្វើអីគេដែរនៅណុងអ៊ុំ?

ខៈ ខ្ញុំហោសភ្ជួរ

កៈ ចឹងអ៊ុំភ្ជួររាស់ណាអ៊ុំ?

ខៈ នឹងហើយភ្ជួររាស់នឹងហាស

កៈ នឹងដកស្ទូងអីដែរនឹងហោសអ៊ុំ?

ខៈ បាទចេះទាំងអស់នឹងហាស

កៈ អ៊ូ!!បាទអ៊ុំ ចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាស
អ៊ុំគិតថាជីវិតរបស់អ៊ុំធ្លាប់បានធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខៈ ធ្វើតែភ្ជួរ ហើយនឹងរកត្រីនឹងហាសស្ទូងដកអីចឹងទៅប្រវត្តិមានតែប៉ុណ្ណឹងហាស

កៈ ចុះអ៊ុំគិតថាអ៊ុំមានធ្លាប់បើកមុខរបរអាជីវកម្មលក់ដូរអីគេដែរទេអ៊ុំ?

ខៈ អត់អត់ទេអត់ដែរមានដើមបើកអីផងនឹង

កៈ ចុះអ៊ុំមានធ្លាប់ចិញ្ចឹមសត្វចិញ្ចឹមអីទេ?

ខៈ ចិញ្ចឹមជ្រូកនឹងហាស

កៈ ចិញ្ចឹមជ្រូកណាអ៊ុំ?

ខៈ ចិញ្ចឹមមាន់ចឹងទៅនឹងហាស នេះកូនប្រសាររបស់ខ្ញុំនឹង

កៈ អ៊ូ!!ចុះអ៊ុំ?

ខៈ ទើបតែការបាន5-6ឆ្នាំទេកូនប្រសារនឹងហាស

កៈ
ចុះអ៊ុំគិតថាអ៊ុំចិញ្ចឹមជ្រូកចិញ្ចឹមមាន់នឹងលក្ខណៈជាគ្រួសារឺចិញ្ចឹមលក្ខណៈជាខ្នាតធំដែរអ៊ុំ?

ខ៖ ចិញ្ចឹមលក្ខណៈជាខ្នាតតូចនឹងហាស

ក៖ អូ៎!!ចិញ្ចឹមលក្ខណៈជាខ្នាតតូចហោសអ៊ុំ?

ខ៖ ចិញ្ចឹមលក្ខណៈជាគ្រួសារនឹង ចុះវាអត់មានដើមហោសចេះតែចិញ្ចឹមទៅតិចៗៗចឹងទៅរួច អាជីវកម្មចឹងទៅណាស់

ក៖ បាទអ៊ុំបាទនឹងហើយ?

ខ៖ ជីវកម្មនឹងកាលជំនាន់ណុងយើងក្រដែរទៅ ដាក់ម៉ងដាក់អីមានត្រីបន្តិចបន្តួចចឹងទៅក៏បានមាន់នឹងខ្លះដែរទៅ

ក៖ បាទអ៊ុំបាទនឹង?

ខ៖ បានលុយចឹងក៏ប៉ាវស្រីការ៉ាអូខេចឹងទៅ

ក៖ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្តូរអីគេដែរទៅអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាសអ៊ុំ?

ខ៖ អត់ទេកាលណុងមានតែប៉ុណ្ណឹងមកទាល់ឥឡូវនឹងហាស

ក៖ អូ៎!!ចឹងទេហោសអ៊ុំ?

ខ៖ កំសត់ដែរនឹងប៉ុន្តែទាល់តែមួយរយៈនឹងបានកូន2-3ឆ្នាំនឹងតើបានជួយចឹងទៅបានធូរទៅ

ក៖ អូ៎!!ធូរបានច្រើនហោសអ៊ុំ?

ខ៖ កាលមុនឹងវេទនាណាស់តែម្តងនឹងនៅតែបឹងចឹងតែម្តងនឹង

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ នឹងហើយរកតែត្រីនឹងហាស បេះត្រកួនចឹងទៅយកមក

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ រាល់តែថ្ងៃទៅបេះដៃរកូនមិនអោយទៅទេប៉ុន្តែខ្ញុំចេះតែទៅចឹងទៅណាស់ បានលុយយើងយកមកអោយមីនេះនៅពៅគេនឹងហាស

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ យើងចេះតែទុកលុយអោយវាខ្លះវិញចឹងទៅណាស់ ចេះតែអោយហូបអោយអីចឹងទៅ

ក៖ អោយបាយអោយអីចឹងទៅ?

ខ៖ នឹងហើយយើងរកខ្លួនឯងខ្លះអីចឹងហាស

ក៖ ចុះអ៊ុំគិតថាអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរទៅអ៊ុំ?

ខ៖ ខ្ញុំហោសខ្ញុំចូលចិត្តសម្លគ្រប់មុខសម្លប្រហើរ សម្លម្ជូរចឹងទៅ ម្ជូរគ្រឿងចឹង ប្រហុកចិញ្រ្ចាំ

ក៖ អូ៎!!ចូលចិត្តសម្លម្ជូរគ្រឿងដែរហោសអ៊ុំ?

ខ៖ អត់មានទេ

ក៖ ចុះកាលពីនៅក្មេងនឹងអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេខ្លះដែរទៅអ៊ុំ?

ខ៖ ចូលចិត្តលេងនឹងចូលចិត្តលេងឈូង លេងអង្គុញនឹង រាំវង្សចឹងទៅហោស អូសប្បាយណាស់

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ ហើយទើបតែឥឡូវនឹងយ៉ាងម៉េចទេនេះបាត់ឈឹងនឹងហាសឆ្នាំនឹងហាស

ក៖ អូចឹងហោសអ៊ុំ?

ខ៖ លេងឈូងនឹងលេងដាច់ក្បាលជង្គង់មួយអស់នឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំមានចេះច្រៀងទេអ៊ុំ?

ខ៖ អត់ចេះទេ

ក៖ ប៉ុន្តែអ៊ុំចូលចិត្តច្រៀងដែរអត់អ៊ុំ?

ខ៖ ចុះមកសំភាសន៍នឹងមកពីខាងណាវិញ?

ក៖  បាទបងមកខាងសកលវិទ្យាល័យមួយដែរនៅអាមេរិចហាសបង

ខ៖  ត្រូវហើយបងជីដូនមួយនៅអាមេរិចនឹង

ក៖  ហើយគេដាក់មួយនឹងទុកអោយកូនចៅខ្មែរបានស្គាល់ពីប្រវត្តិឪពុកម្តាយ
ទុកអោយកូនចៅរបស់គាត់បានស្តាប់ចឹងហាសបង?

ខ៖  ហើយម៉េចបានអូនឯងមកសំភាសន៍គាត់ចឹង

ក៖  ដោយសារតែយើងមកសំភាសន៍ប្រជាជនខ្មែរទាំងអស់នឹងហាសបង
ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយទេបង?

ខ៖  ស្មានតែទៅយកអីមកជួយខ្មែរ

ក៖  អូ!!អត់ផងនឹងបង ប៉ុន្តែអ៊ុំចូលចិត្តច្រៀងទេ?

ខ៖  ចូលចិត្តតែរាំនឹងគាត់ច្រៀងអត់កើតទេប៉ុន្តែចង់ច្រៀងណាស់នឹង

ក៖  អូ!!ចឹងហោសអ៊ុំ?

ខ៖  បាទនឹងហើយ

ក៖  ប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀង?

ខ៖  បាទនឹងចូលចិត្ត

ក៖  ប៉ុន្តែលក្ខណះបទសម័យរឺមួយក៏បទបុរាណដែរអ៊ុំ?

ខ៖  ដូចបទញីកែងជើងអីចឹង ទេដូចបទស៊ិស៊ីសាម៉ុតអីចឹងទៅណាស់

ក៖  អូ!!ចឹងទេហោសអ៊ុំ?

ខ៖  បាទដូចជាណយ វ៉ាន់ណេត កែវសារ៉ាត់ អីចឹងទៅ

ក៖  អូ!!ចឹងហោសអ៊ុំ?

ខ៖  បើបុរាណនឹងចូលចិត្តស្តាប់ទាំងអស់ ប៉ុន្តែឥឡូវនឹងមិនសូវទេនឹង។

ក៖  អូ!!ចឹងហោសអ៊ុំ?

ខ៖ ចេះនេះទេចេះតែលេងសើចចឹងទៅ កាលពីមុននឹងចូលចិត្តស្តាប់ទាំងអស់នឹងហាស អាបទបុរាណនឹងហាស។

ក៖ ចុះអ៊ុំមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ភ្លេងដែរទេ ឧទាហរណ៍ថាលក្ខណះភ្លេងខ្មែរ?

ខ៖ ភ្លេងខ្មែរនឹងអត់មានទេ។

ក៖ នឹងភ្លេងសៀមអីចឹងហាស?

ខ៖ ខ្ញុំនៅនេះនឹងអត់មានទេ ចៅនឹងក៏អត់មានដែរនឹង។

ក៖ បងប្អូនអីក៏អត់មានចេះលេងដែរហោសអ៊ុំ?

ខ៖ បងប្អូនណោះមាននោះខាងពិនពាតនឹងហាសក្មួយ។

ក៖ ចឹងហោសអ៊ុំ?

ខ៖ បាទក្មួយនឹងហាស បើក្មួយនឹងមានម៉ាកំណរនឹងនៅលើហោស ចេះលេងភ្លេងពិនពាតចេះ។

ក៖

ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ ផ្ទះកាលនៅពីក្មេងហោស។

ក៖ បាទអ៊ុំបាទ?

ខ៖ ផ្ទះកាលនៅពីក្មេងនឹងនៅជាមួយឪពុករបស់ខ្ញុំនឹងផ្ទះក្បឿង ប៉ុន្តែជញ្ជាំងស្លឹក ប៉ុន្តែធំហាសណាស់។

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ បណ្តោយនឹងចូល15ម៉ែត្រហោស។

ក៖ បាទៗៗនឹងអ៊ុំ?

ខ៖ បណ្តោយពីសង្គមហាស ហើយជញ្ជាំងនឹងស្លឹក ហើយរនាបនឹងឬស្សីនឹង។

ក៖ បាទអ៊ុំបាទ?

ខ៖ នឹងកាលពីជំនាន់ខ្ញុំនៅតូចចឹងទៅណាស់។

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ហើយមកដល់ឥឡូវនឹងផ្ទះរបស់ខ្ញុំនឹងមានតែប៉ុណ្ណឹង។

ក៖ ប៉ុន្តែនរណាគេជាអ្នកសាងសងដែរអ៊ុំ?

ខ៖ ខ្ញុំខ្លួនឯងនឹងហាស។

ក៖ អ៊ុំចេះធ្វើផ្ទះហោសអ៊ុំ?

ខ៖ ជួយធ្វើគេចឹងទៅ យកគេមួយចឹងទៅយើងធ្វើជាមួយគ្នាចឹងទៅណាស់។

ក៖ គេធ្វើខ្លះនឹងយើងធ្វើខ្លះដែរចឹងហោសអ៊ុំ?

ខ៖ បាទកូនអីនឹងជួយធ្វើចឹងទៅនឹង។

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ ចុះយើងថវិការតិចនោះអី។

ក៖ បាទអ៊ុំ ចុះអ៊ុំគិតថាអ៊ុំមានចេះជំនាញអីដែរអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខ៖ ចេះស្ទាត់ហោសនឹង?

ក៖ បាទអ៊ុំចេះអីគេដែរទៅ?

ខ៖ បើនិយាយទៅនឹងដដែលនឹងមុខរបរមានតែត្រកួនរកត្រីអីនឹង។

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ ហើយនឹងធ្វើស្រែអីនឹងហាស។

ក៖ អូ៎!!បាទអ៊ុំបាទ
ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងតាំងពីក្មេងនឹងអ៊ុំមានជួបការលំបាកអីគេខ្លះដែរទៅអ៊ុំ?

ខ៖ លំបាកនឹងយើងនៅបឹងដាក់ម៉ងសន្ទូចនឹងតែម្តងនឹង។

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ខ្ញុំកំសត់ណាស់នឹង។

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ សន្ទូចម៉ងនឹងមួយថ្ងៃៗនឹង។

ក៖ ចុះអ៊ុំគិតថាកាលពីក្មេងនឹងអ៊ុំមានការលំបាកអីគេដែរទៅអ៊ុំ?

ខ៖ មានការលំបាករត់គ្រាប់ផ្លោងនឹង។

ក៖ អូ៎!!រត់គ្រាប់ផ្លោងហោសអ៊ុំ?

ខ៖ បាទនឹងហើយ។

ក៖
ចុះអ៊ុំគិតថាកាលពីជំនាន់ពលពតនឹងជំនាន់លុណនុលនឹងអ៊ុំធ្លាប់ជួបការលំបាកអីគេដែរទៅអ៊ុំ?

ខ៖ ជំនាន់លុនណុលនឹងខ្ញុំរត់គ្រាប់ផ្លោងនឹងហាស
អើយនិយាយពីផ្លោងទៅក្របៅអាចម៍កុកនឹង
ខ្ញុំចង់សំភាសន៍លេងទុកអោយបងខ្ញុំស្តាប់ចឹងហាស។

ក៖ អត់អីទេអ៊ុំចាំបន្តិចទៀតនឹងខ្ញុំសំភាសន៍អ៊ុំចឹងហាស។

ខ៖ និយាយពីគ្រាប់ផ្លោងនឹង។

ក៖ ចឹងហោសអ៊ុំ?

ខ៖ ផ្លោងទៅនាំគ្នាវេទនាណាស់នឹង នៅក្នុងប៉ាវពួននឹងហាស។

ក៖ បាទអ៊ុំបាទ?

ខ៖
ពូននៅក្នុងប៉ារនឹងហើយនិយាយពីថាពិបាកវេទនាទៅណាស់ពិបាកនៅក្នុងជំនាន់លុនណុល នឹងតែម្ដងនឹងហាស។

ក៖ បាទអ៊ុំបាទនឹងហោស?

ខ៖ ដល់ពេលដែរអាពតនឹងគេអោយបោចស្មៅនឹង
គេអោយអីចឹងទៅគេអោយរែកដីនឹងហាស។

ក៖ ចឹងណាអ៊ុំណា?

ខ៖
គេអោយរែកដីអាបង្គីធុងសាំងនឹងគេកាត់ជាពីរកាលពីក្មេងៗហាសចុះយើងនៅសប្បាយហាស កាលណុងយើងនៅចូរដែរហោស។

ក៖ ប៉ុន្តែពេលណុងអ៊ុំនៅអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ យើងអាយុច្រើនដែរតើអាយុ17-18ឆ្នាំហើយប៉ុន្តែយើងក្រិនហោសនឹង។

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ យើងក្រិនយើងក្រះនឹងហាស ដើររែកហើយចេះតែដើរតះតាស់
យើងចេះតែសប្បាយចឹងទៅណាស់ មិនដឹងស្លាប់មិនដឹងអីទេចេះតែទៅហើយនឹងហាស។

ក៖ យើងចេះតែទៅហើយនឹងអ៊ុំ?

ខ៖ គេអោយធ្វើនឹងចេះតែធ្វើទៅនឹងហាសបាទកាលពីជំនាន់ណុងហាស។

ក៖ បាទចុះអ៊ុំគិតថាកាលពីជំនានពលពតនឹងអ៊ុំមានការលំបាកអីគេខ្លះដែរទៅអ៊ុំ?

ខ៖ លំបាកគេកៀបសង្កត់នឹងហាសយើងដើរទាល់តែត្រង់ផ្លឹងហោស
បើយើងអស់ស្រួលហាសជួនកាលនឹងគេយកទៅសំលាប់ចោលហាស
ហើយគេចង់សម្លាប់យើងទៀតចឹងទៅណាស់។

ក៖ បាទអ៊ុំបាទនឹង?

ខ៖ យើងចេះតែធ្វើការងារចឹងទៅ យើងធ្វើអត់ដឹងអត់លឺទៅនឹងហាស។

កៈ បាទចុះពេលណុងគេអោយទៅធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខៈ ទៅនឹងគេមានអោយទៅនេះនឹងទៅរែកអាចម៍គោ នឹងកាប់កន្រ្តាំងខែត។

កៈ ប៉ុន្តែពេលណុងអ៊ុំគេអោយជំលាស់ទៅណាដែរទៅអ៊ុំ?

ខៈ នេះនៅព្រែកហូរនឹងហាស។

កៈ អូ៎!!អ៊ុំនៅព្រែកហូរហោសអ៊ុំ ចុះអ៊ុំនៅជាកងចល័តគេរឺយ៉ាងណាដែរអ៊ុំ?

ខៈ ខ្ញុំនៅកងកុមារនឹងហាស។

កៈ នៅកងកុមារណេអ៊ុំ?

ខៈ ខ្ញុំវាត្រូវយុវជនតែត្រូវវានៅតូចពេកនឹងគេអោយនៅកុមារនឹងហាស។

កៈ អូ៎!!នៅកងកុមារចឹងហោសអ៊ុំ?

ខៈ បាទនឹងកងកុមារនឹង។

កៈ អូ៎!!បាទចុះអ៊ុំ?

ខៈ ចុះនៅប៉ុននេះនឹងអាយុ17-18ប៉ុន្តែខ្ញុំនៅក្រិនហោស ខ្ញុំនៅក្រិននឹងហាស។

កៈ បាទអ៊ុំចុះ?

ខៈ ចុះមានពុទត្បុតអីទេពេលសុំគេទៅបទជើងនឹងមានទៅគូរក្រឡារែកអីទេ ប៉ុន្តែខ្ញុំពេលដែរហាត់នឹង លួចគេចខ្លាចដែរចឹងទៅ។

កៈ ចុះអ៊ុំគិតថាពេលណុងគេអោយអ៊ុំនៅជាមួយក្រុមគ្រួសាររឺមួយក៏អោយអ៊ុំជាកងកុមារទេអ៊ុំ?

ខៈ នៅជាមួយកងកុមាររហូតនឹងហាសអស់3ឆ្នាំនឹង8ខែនឹងហាស នៅរហូតនឹង។

កៈ ប៉ុន្តែអ៊ុំគេអោយរែកតែដីទេណអ៊ុំ?

ខៈ បាទនឹងហើយរែកដី បោចស្មៅក្នុងស្រូវនឹងកាប់កន្រ្តាំងខែត រែកអាចម៍គោ។

កៈ ចុះរបបអាហារអីយ៉ាងម៉េចដែរទៅអ៊ុំ?

ខ៖ របបអាហារនឹងហូបល្មមនឹងជូនកាលទៅដាក់បបរគោកចឹងទៅ
ជូនកាលទៅបាយបិះៗៗចឹងទៅ។

ក៖ បាទៗៗបាទអ៊ុំបាទ?

ខ៖ លាយត្រកួននឹងខខ្ទុរអីចឹងទៅណាស់។

ក៖ បាទអ៊ុំបាទនឹង?

ខ៖ មានខ្មៅទឹកបិះៗៗចឹងទៅណាស់ចេះតែហូបចឹងទៅ។

ក៖ បាទអ៊ុំបាទនឹង?

ខ៖ អោយចេះតែរស់ៗៗទៅនឹងហាស។

ក៖ ចុះរហូតទាល់តែដាច់ពលពតថ្មីៗៗនឹងអ៊ុំធ្វើអីគេដែរទៅអ៊ុំ?

ខ៖ ខ្ញុំបានចេញមកវិញនឹងហាស។

ក៖ នៅក្នុងឆ្នាំប៉ែតជាងនឹងហាស?

ខ៖ នៅឆ្នាំប៉ែតជាងហោស នៅឆ្នាំ1979ហី?

ក៖ អ៊ុំ!!បាទនៅឆ្នាំ1979នឹង?

ខ៖ នឹងខ្ញុំធ្វើស្រែធ្វើចំការនឹងជំនាន់។

ក៖ ប៉ុន្តែពេលណុងអ៊ុំបានមកនៅជាមួយគ្រួសារហើយណអ៊ុំ?

ខ៖ ខ្ញុំមកនៅជាមួយគ្រួសារជាមួយម្តាយនឹងខ្ញុំអត់ទាន់មានប្រពន្ធទេនឹង។
ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ នឹងហើយនៅជាមួយម្តាយនឹងហាសធ្វើស្រែនឹង។

ក៖ ចុះរហូតដល់អ៊ុំមានគ្រួសារនឹងអ៊ុំគិតថាអ៊ុំមានការលំបាកអីគេដែរទៅអ៊ុំ?

ខ៖ កាលលំបាកនឹងវេទនារឿងដាក់ម៉ងដាក់អីនឹងកូនអើយវេទនាណាស់
ចុះដីបឹងនឹងគេមិនមានដង្កៅ។

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖  ចុះនៅពេលដែរយើងដាក់ចឹងទៅគេមិនចាប់យកម៉ងនឹងហាស។

ក៖  ទាល់តែយើងទៅសុំគេមែនទេអ៊ុំ?

ខ៖  ចុះយើងទៅសុំគេប៉ុន្តែគេមិនអោយទេនឹង។។

ក៖  អូ៎!!ចឹងហោសអ៊ុំ?

ខ៖  គេមិនអោយយើងទេហើយយកទៅអស់ៗៗតែម្តងនឹងហើយយើងទិញទៀតចឹងទៅ។

ក៖  អូ៎!!ចឹងហោសអ៊ុំ?

ខ៖

ទៅជឿបងប្អូនចាមចឹងទៅគេអោយបានមួយដៃពីរដៃចឹងទៅដាក់ទៀតចឹងកំសត់ណាស់នឹង ដល់ហើយគេយកទៀតចឹងទៅ

ក៖ ដាក់បានគេយកទៅទៀតចឹងទៅ?

ខ៖  នឹងហើយគេយកទៀតចឹងទៅនឹង

ជូនកាលយើងនៅព្រំប្រទល់ណៃជីរាស្រ្តនឹងហាស។

ក៖  បាទអ៊ុំម៉េចទៅ?

ខ៖  អត់មានត្រូវទេទាល់តែទៅលួចគេ។។

ក៖  អូ៎!!ចឹងហោសអ៊ុំ?

ខ៖  ទាល់តែយកទៅផ្លោងនៅដីដង្ហៅនឹងបានត្រូវដីឡូនឹងហាស។

ក៖  ប៉ុន្តែឥឡូវនឹងជីវភាពរបស់អ៊ុំនឹងបានធូរធារជាងមុនហើយណាអ៊ុំ?

ខ៖  បានធូរកូនចិញ្ចឹមនឹងហាស។

ក៖  បាទអ៊ុំបាទនឹងហោស?

ខ៖  បានកូនធំចិញ្ចឹមនឹងហាស។

ក៖  បាទអ៊ុំចុះអ៊ុំគិតថាអ៊ុំបានឆ្លងកាត់ការលំបាកទាំងអស់នឹងដោយរបៀបណាដែរទៅអ៊ុំ?

ខ៖ របៀបវាយើងចេះតែអត់ដើមអត់អីនឹងយើងចេះតែ លំបាកវេទនាចឹងហាសអូន យើងក្រហាសចុះថាម៉េចយើងក្រហាស វាអត់មានហាស។

ក៖ បាទអ៊ុំបាទនឹងហោស?

ខ៖ បានចាប់ដៃគ្នាមកដូចជាអត់មានដើមរកស៊ីតែម្ដងនឹងហាស ម្ដាយក៏អត់ខាងស្រីខាងប្រុសនឹងក៏គាត់អត់មានដែរទាំងអស់ទាំងសងខាងនឹងហាស។

ក៖ ចឹងយើងចាប់ផ្ដើមរកខ្លួនយើងណាអ៊ុំ?

ខ៖ បាទយើងរកតែខ្លួនយើងនឹងហាស។

ក៖
បាទអ៊ុំចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់អ៊ុំដែរទៅ?

ខ៖ នេះសប្បាយដែរកូនអោយធូរឥឡូវនឹងវារៀងធូរដែរចឹងនឹងហាស។

ក៖ បាទអ៊ុំបាទនឹង?

ខ៖ យើងសប្បាយបន្តិចទៅណាស់វាមិនទាន់អីនេះទេ សប្បាយដែរពេលដែរកូននាំទៅលេងនៅព្រះវិហារ។

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ បាទទៅបូកគោចឹងហាសឥឡូវនឹង

ក៖ អូ៎!!អ៊ុំដើរលេងដែរហោសអ៊ុំ?

ខ៖ បាទនឹងហើយនឹង ទៅកំពត់ទៅកំពង់សោមអីនឹងហាស ទៅអង្គរវត្តអីចឹងទៅ។

ក៖ អូ៎!!បាទអ៊ុំបាទនឹង?

ខ៖ ទៅប៉ៃលិននឹងហាស។

ក៖ បាទអ៊ុំបាទ?

ខ៖ ទៅបន្ទាយមានជ័យចឹងទៅណាស់។

កៈ
ចុះអ៊ុំគិតថាតាំងពីក្មេងនឹងអ៊ុំគិតថាអ៊ុំស្រម៉ៃថាចង់ធ្វើអីដែរទេពេលដែរធំឡើងចឹងហាស?

ខៈ ក្តីស្រម៉ៃនឹងមានតែថាពេលដែរចាស់នឹងទៅអោយបានសប្បាយ
កុំអោយកើតទុកអោយកូនធូរធារ
អីចឹងទៅអោយយើងបានមានសុខទុកទៅណាស់កុំអោយ ថាពិបាកអីចឹងទៅណាស់។

កៈ បាទអ៊ុំបាទនឹង?

ខៈ អោយបាននៅផ្ទះនឹងនៅមើលតែចៅនឹងមើលអីចឹងទៅ កុំអោយថាពិបាកដូចពីមុន។។

កៈ កុំអោយដូចពីមុនៗៗចឹងហោសអ៊ុំ?

ខៈ បាទនឹងហាសពីមុនចឹងទៅណាស់ នឹងខ្ញុំស្រម៉ៃតែប៉ុណ្ណឹង។

កៈ បាទអ៊ុំបាទនឹងហាស?

ខៈ ប៉ុន្តែវាមិនបានដូចប្រាថ្នានឹងហាស។

កៈ ទៅអោយបានដូចសេចក្តីបំណងនឹងហោសអ៊ុំ?

ខៈ បាទនឹងហើយចឹង អោយបានដូចបំណងនឹងហាស។

កៈ
ចុះបើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗនឹងតើអ៊ុំចង់ផ្តែផ្តាំអីទៅពួកគាត់ដែរអ៊ុំ?

ខៈ ផ្តែអីនឹងកូនជំនាន់ក្រោយនឹងកុំអោយវាសេបគ្រឿងញៀន ដើរលេងខុសផ្លូវអីចឹងទៅ ដឹងតែយើងរៀនសូត្រអីចឹងទៅ ដឹងតែល្អចឹងទៅណាស់។

កៈ អូ៎!!បាទអ៊ុំបាទនឹង?

ខៈ អោយដូចកូនខ្មែរអោយល្អចឹងទៅ កុំអោយម៉ែឪពិបាកចិត្តអីចឹងទៅណាស់
អោយដើរតែត្រង់។

កៈ អោយតាមកន្លងធិមអីចឹង?

ខៈ អោយតាមកន្លងធិមអីចឹងទៅកូនណាស់។

កៈ ចុះបើសិនជាអ៊ុំចង់អោយគាត់រៀសរៀងវិញ
តើអ៊ុំចង់អោយពួកគាត់រៀសវៀងអីគេវិញដែរអ៊ុំ?

ខៈ ជៀសវៀងគ្រឿងញៀននឹងតែម្តងនឹងហាសតែម្តងនឹងហាស។

កៈ អ៎ូ!!បាទអ៊ុំបាទ?

ខៈ វាពិបាកណាស់រាល់ថ្ងៃនឹងហាសខ្ញុំឃើញស្តមៗៗកូនអើយ។

កៈ បាទអ៊ុំបាទនឹង?

ខៈ ហើយប៉ូលីសចាប់យកទៅរាល់តែថ្ងៃនឹងអត់រៀងទៀតនឹងហាស។

កៈ ត្រូវហើយអ៊ុំពួកគាត់ញៀនណាអ៊ុំ?

ខៈ បាទនឹងហើយ អូយកូនអើយម្តាយឪពុកគេអត់លុយដើររកលុយគេយកទៅបង់នឹង។

កៈ អ៎ូ!!បាទអ៊ុំបាទនឹង?

ខៈ វាចឹងហាស ហើយវានឹងអត់រៀងតែម្តងនឹងហាស។

កៈ បាទអ៊ុំបាទនឹង?

ខៈ ចង់អោយវារៀងនឹងតែម្តងនឹងហាសកូនអើយ។

កៈ បាទអ៊ុំត្រូវហើយនឹងអ៊ុំ?

ខៈ ហើយប៉ូលីសនឹងវាមិនធ្វើចឹងទេវាចឹងពេញភូមិនឹងហាស។

កៈ បាទអ៊ុំបាទនឹង?

ខៈ ជួនកាលវាដើរលួចកង់លួចអីយើងចឹងទៅណាស់កូន។

កៈ បាទអ៊ុំបាទនឹង?

ខៈ ជួនកាលលួចកងគេអីចឹងទៅ ចុះបើវាខូចអស់រលីងហើយនឹងហាស។

កៈ បាទត្រូវហើយអ៊ុំនឹង ចុះមានអីចង់ផ្តែផ្តាំទៀតទេអ៊ុំ?

ខៈ មានការផ្តែផ្តាំយ៉ាងម៉េចដែរទៅអូន។

កៈ ចុះអ៊ុំមានអីចង់ផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយអីផ្សេងទៀតទេនឹង?

ខៈ ចង់ផ្ដែផ្ដាំអោយមើលទឹកដីយើងអោយល្អ អោយគង់វង្ស ស្ថិតស្ថេរចឹងទៅណាស់។

កៈ បាទអ៊ុំបាទនឹង?

ខៈ អោយបានរីកចំរើនចឹងទៅមុខនឹងអោយបានដឹងសំបូរសប្បាយដែរនឹងហាស
កុំអោយទឹកដីរួញចឹងទៅ។

កៈ បាទអ៊ុំបាទនឹង?

ខៈ
អោយសប្បាយចឹងទៅនឹងហាសកូនខ្មែរនឹងកុំអោយមានសង្គ្រាមអីចឹងទៀតនឹងហាស។

កៈ បាទអ៊ុំបាទ ចុះមានអីផ្សេងទៀតទេអ៊ុំ?

ខៈ អត់ហើយ តែខ្ញុំអស់នឹងគឺអស់តាមខ្ញុំនឹងហាស។

កៈ បាទអ៊ុំចឹងជាចុងក្រោយនឹងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់អ៊ុំ
ហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលា
ដើម្បីទុកអោយកូនចៅជំនាន់ ក្រោយៗៗរបស់អ៊ុំបានស្គាល់នឹងបានដឹង
នឹងបានស្គាល់ពីប្រវត្តិរបស់អ៊ុំនឹង។

ខៈ បាទប្រវត្តិរបស់ខ្ញុំនឹងមានតែចឹងទេនឹង។

កៈ នឹងបានស្គាល់ពីប្រវត្តិឪពុកម្ដាយចឹងហាសអ៊ុំ បាទអរគុណច្រើនអ៊ុំ។

ខៈ ប្រវត្តិយើងអ្នកក្រកូនអើយមានតែប៉ុណ្ណឹង។

កៈ បាទអ៊ុំបាទអរគុណច្រើនអ៊ុំ។